ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:១៨៧.អនក្រ.បក

អនុក្រឹត្យ
ស្តីពី
ការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈកម្មការថ្នាក់ជាតិ ពិនិត្យ និង ទាយតម្លៃ បញ្ជីឈ្មោះឧណ្ហិតស្នើសុំបន្ធូរបន្ថយទោស និងលើកលែងទោស

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១១/០២១ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ ២០១១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីពន្ធនាគារ
- បានឃើញក្រឹត្យលេខ ២៨ក្រ ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ ១៩៨៨ របស់ក្រុមប្រឹក្សារដ្ឋ នៃសាធារណរដ្ឋប្រជាមានិតកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ១៩ អនក្រ ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងយុត្តិធម៌
- បានឃើញអនុក្រឹត្យលេខ ១៤៨ អនក្រ.បក ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០០៦ ស្តីពីការបង្កើតអគ្គនាយកដ្ឋានពន្ធនាគារ
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បន្ទាប់ពីមានការឯកភាពពីរដ្ឋមន្ត្រីក្រសួងយុត្តិធម៌

សម្រេច

មាត្រា ១ .-

ត្រូវបានបង្កើតគណៈកម្មការថ្នាក់ជាតិពិនិត្យ និងវាយតម្លៃបញ្ជីឈ្មោះទណ្ឌិតស្នើសុំបន្ធូរបន្ថយទោស និងលើកលែងទោស ដែលមានសមាសភាព ដូចខាងក្រោម :

១- រដ្ឋមន្ត្រីក្រសួងយុត្តិធម៌	ជាប្រធាន
២- រដ្ឋលេខាធិការក្រសួងមហាផ្ទៃ ទទួលបន្ទុកកិច្ចការពន្ធនាគារ	ជាអនុប្រធានអចិន្ត្រៃយ៍
៣- អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍	ជាអនុប្រធាន
៤- តំណាងក្រុមប្រឹក្សាអ្នកច្បាប់ទីស្តីការគណៈរដ្ឋមន្ត្រី ០១រូប	ជាសមាជិក
៥- ប្រធានក្រុមប្រឹក្សានីតិកម្មក្រសួងមហាផ្ទៃ	ជាសមាជិក
៦- តំណាងក្រសួងយុត្តិធម៌ ០១រូប	ជាសមាជិក
៧- អគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធនាគារ	ជាសមាជិក
៨- តំណាងអគ្គស្នងការដ្ឋាននគរបាលជាតិ ០១រូប	ជាសមាជិក
៩- តំណាងអគ្គនាយកដ្ឋានបច្ចេកទេសក្រសួងយុត្តិធម៌ ០១រូប	ជាសមាជិក
១០- ប្រធាននាយកដ្ឋានប្រតិបត្តិ	ជាសមាជិក
១១- ប្រធាននាយកដ្ឋានអប់រំកែប្រែ	ជាសមាជិក
១២- ប្រធានលេខាធិការដ្ឋានគណៈកម្មការថ្នាក់ជាតិ	ជាលេខាធិការ

មាត្រា ២ .-

គណៈកម្មការនេះ មានសិទ្ធិនិងការកិច្ច ដូចខាងក្រោម ៖

- ធ្វើការផ្សព្វផ្សាយខ្លឹមសារនៃសេចក្តីណែនាំរបស់ក្រសួងមហាផ្ទៃ អំពីលក្ខណៈសម្បត្តិ និងចំណាត់ថ្នាក់ប្រឡងប្រណាំងខិតខំកសាង កែប្រែគំនិតមារយោទរបស់ទណ្ឌិតម្នាក់ៗក្នុងរយៈពេលរងទោសនៅមណ្ឌលអប់រំកែប្រែ និងនៅពន្ធនាគារាជធានី ខេត្ត
- ធ្វើការណែនាំដល់គណៈកម្មការរាជធានី ខេត្តនិងគណៈកម្មការក្រសួងមហាផ្ទៃ អំពីរបៀបគិតគូរយៈពេលរងទោសក្នុងមណ្ឌលអប់រំកែប្រែ និងពន្ធនាគាររាជធានី ខេត្ត និងរបៀបវាយតម្លៃកម្រិតនៃការកែប្រែនិងលក្ខណៈសម្បត្តិរបស់ទណ្ឌិតដែលត្រូវស្នើសុំបន្ធូរបន្ថយទោស និងលើកលែងទោស
- ធ្វើការជំរុញតាមដានលើកដល់គណៈកម្មការរាជធានី ខេត្ត និងគណៈកម្មការក្រសួងមហាផ្ទៃឱ្យរួសរាន់បញ្ជូនបញ្ជីឈ្មោះទណ្ឌិតដែលត្រូវស្នើសុំបន្ធូរបន្ថយទោសនិងលើកលែងទោសមកគណៈកម្មការថ្នាក់ជាតិឱ្យបានទាន់ពេលវេលាតាមការកំណត់នៃច្បាប់
- ពិនិត្យរបាយការណ៍វាយតម្លៃអំពីកម្រិតកែប្រែរបស់ទណ្ឌិតម្នាក់ៗក្នុងរយៈពេលរងទោសនៅមណ្ឌលអប់រំកែប្រែ និងនៅពន្ធនាគាររាជធានី ខេត្ត

- ធ្វើការផ្ទៀងផ្ទាត់រយៈពេលរងទោសក្នុងពន្ធនាគាររបស់ទណ្ឌិតម្នាក់ៗ តាមបញ្ជីឈ្មោះទណ្ឌិតស្នើសុំបន្ធូរបន្ថយទោសនិងលើកលែងទោសជាមួយរយៈពេលរងទោសដែលកំណត់នៅក្នុងសាលក្រម ឬសាលដីការបស់តុលាការ
- ពិនិត្យ និងសម្រេចបញ្ជីឈ្មោះទណ្ឌិត ដែលត្រូវស្នើសុំបន្ធូរបន្ថយទោស និងលើកលែងទោសរបស់គណៈកម្មការរាជធានី ខេត្ត និងគណៈកម្មការក្រសួងមហាផ្ទៃ
- រៀបចំបែបបទជូនរាជរដ្ឋាភិបាលពិនិត្យ និងសម្រេច ដើម្បីធ្វើសំណើថ្វាយព្រះមហាក្សត្រសុំបន្ធូរបន្ថយទោស និងលើកលែងទោសឱ្យទណ្ឌិត
- អញ្ជើញប្រធានគណៈកម្មការរាជធានី ខេត្ត ឬប្រធានគណៈកម្មការក្រសួងមហាផ្ទៃ ឬបុគ្គលពាក់ព័ន្ធផ្សេងទៀត ឱ្យមកបំភ្លឺប្រសិនបើយល់ឃើញថាចាំបាច់។

<u>មាត្រា ៣</u> .-

សមាជិកគណៈកម្មការថ្នាក់ជាតិពិនិត្យ និងវាយតម្លៃបញ្ជីឈ្មោះទណ្ឌិតស្នើសុំបន្ធូរបន្ថយទោស និងលើកលែងទោសត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន។ ក្នុងករណីប្រធានអវត្តមាន អនុប្រធានអចិន្ត្រៃយ៍មានសិទ្ធិកោះអញ្ជើញ និងដឹកនាំអង្គប្រជុំជំនួសតាមការប្រគល់សិទ្ធិរបស់ប្រធាន។

<u>មាត្រា ៤</u> .-

គណៈកម្មការថ្នាក់ជាតិពិនិត្យ និងវាយតម្លៃបញ្ជីឈ្មោះទណ្ឌិតស្នើសុំបន្ធូរបន្ថយទោស និងលើកលែងទោសមានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងយុត្តិធម៌។

<u>មាត្រា ៥</u> .-

គណៈកម្មការថ្នាក់ជាតិពិនិត្យ និងវាយតម្លៃបញ្ជីឈ្មោះទណ្ឌិតស្នើសុំបន្ធូរបន្ថយទោស និងលើកលែងទោស ត្រូវមានលេខាធិការដ្ឋានមួយដែលមានទីតាំងនៅក្នុងទីស្តីការរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

<u>មាត្រា ៦</u> .-

លេខាធិការដ្ឋានគណៈកម្មការថ្នាក់ជាតិត្រូវដឹកនាំដោយប្រធានមួយរូបនិងមានអនុប្រធានមួយចំនួនជាជំនួយការ។ មន្ត្រីបម្រើការងារក្នុងលេខាធិការដ្ឋាននេះ ត្រូវបានជ្រើសរើសចេញពីមន្ត្រីក្របខ័ណ្ឌរបស់ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ និងក្រសួងយុត្តិធម៌។

<u>មាត្រា ៧</u> .-

សមាសភាព និងការកិច្ចរបស់លេខាធិការដ្ឋាន ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

<u>មាត្រា ៨</u> .~

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

<u>មាត្រា ៩</u> .~

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នដែលមានការពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃ[illegible] ឆ្នាំ ២០១២

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានយកសេចក្តីជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
នៃព្រះរាជាណាចក្រកម្ពុជា សូមចុះហត្ថលេខា។

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ***រដ្ឋមន្ត្រីក្រសួងយុត្តិធម៌***

ស ខេង

អ្នក-ឧត្តមឫទ្ធានុ

<u>កន្លែងទទួល</u> :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ឧកញ្ញាលេខាធិការដ្ឋានសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៩
- ឯកសារ-កាលប្បវត្តិ